

# ឆ្កែរបុិលរប៉ូច

Let's Read
The Asia Foundation



រឿង កូនឆ្កែរបិុលរប៉ូច

អ្នកនិពន្ធ៖ កាន់ចាន់ បានណឺជី

អ្នកគំនូរ៖ ឌីប៉ា បាល់សារ៉ា



គ្រួសារយើងមានគ្នាបួននាក់។ ខ្ញុំតែងតែទៅតាម ជិនគូ គ្រប់ទីកន្លែង។



ខ្ញុំត្រូវមើលថែជិនគូគ្រប់ពេល។ មើលចុះ! ខ្ញុំមានអាយុច្រើនជាងគាត់។



ពេលខ្លះ ជិនគូធ្វេសប្រហែសណាស់។ ដូច្នេះ តួនាទីរបស់ខ្ញុំគឺត្រូវយាមផ្ទះ។



យើងតែងតែធ្វើអ្វីៗជាមួយគ្នា។ យើងធ្វើការជាមួយគ្នា។



យើងលេងជាមួយគ្នា។



យើងក៏ទទួលការស្តីបន្ទោសពីម៉ែជាមួយគ្នាដែរ។



ខ្ញុំតែងតែជួយម៉ែ នៅពេលដែល ជិនគូ ទៅសាលារៀន។ ខ្ញុំជួយដេញសត្វក្អែកកុំឱ្យស៊ីនំរបស់ម៉ែ។



ថ្ងៃនេះ ជិនគូ ក្លាយជាគ្រូរបស់ខ្ញុំ។ ទីបំផុត ខ្ញុំចេះមេរៀនថ្មីមួយទៀត។



ខ្ញុំគឺជាកូនឆ្កែដ៏ល្អ។ ខ្ញុំមិនបន្លាចកូនឆ្មាទេ។



តើឯងគឺជាមិត្តរបស់ ជិនគូ មែនទេ? អ៊ីចឹង ឯងក៏ជាមិត្តរបស់ខ្ញុំដែរ។



ចូរអានឈ្មោះទាំងនេះ។ តើប្អូនចូលចិត្តធ្វើសកម្មភាពណាខ្លះ?

ខ្ញុំចូលចិត្តរាំ។

ខ្ញុំចូលចិត្តហែលទឹក។

ខ្ញុំចូលចិត្តលោតអន្ទាក់។

ខ្ញុំចូលចិត្តគូរគំនូរ។





ខ្ញុំចូលចិត្តជិះកង់។
ខ្ញុំចូលចិត្តឡើងភ្នំ។
ពេលខ្លះ យើងនិយាយថា «ស្មោះត្រង់ដូចសត្វឆ្កែ»។ យើងនិយាយបែបនេះ ពីព្រោះឆ្កែតែងតែនៅជិតម្ចាស់វារហូត។
ប្រសិនបើឆ្កែនោះដើរឆ្ងាយឬវង្វេង វាតែងតែស្វែងរកផ្លូវត្រលប់មកផ្ទះវិញបានជានិច្ច។

n/a

n/a

n/a

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*Naughty Dog*, Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/

Contributing translators: Brian, Sreynich Sun, Nivatana Phea, Rattana Huy chheng, and Sodany Ouch